វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី០៣ ខែសីហា ២០១៨**

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺ៖

- ធនាគារជាតិនៃកម្ពុជាបានដាក់បញ្ចូលសន្ទនីយភាព ២៣៨ ប៊ីលាន រៀល ទៅក្នុងកម្មវិធីកម្ចី
- វៀតណាមជាប់ជាដៃគូពាណិជ្ជកម្មអាស៊ានធំបំផុតរបស់ចិនបន្ទាប់ពីម៉ាឡេស៊ី
- កំណើនផលិតផលក្នុងស្រុកសរុបរបស់អាមេរិកឡើងដល់៤,១%នៅក្នុងត្រីមាសទី២

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗ នៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារ បណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធ របស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះ មានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តនៅក្នុងការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ធនាគារជាតិនៃកម្ពុជាបានដាក់បញ្ចូលសន្ទនីយភាព ២៣៨ ប៊ីលាន រៀល ទៅក្នុងកម្មវិធីកម្ចី

ដើម្បីរួមចំណែកក្នុងការបង្កើនលទ្ធភាពលើកកម្ពស់ការប្រើប្រាស់រូបិយប័ណ្ណក្នុងស្រុក ធនាគារជាតិនៃកម្ពុជាបានបញ្ចូលទឹកប្រាក់ជាង២៣៨ ប៊ីលានរៀល ទៅអោយធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សម្រាប់កិច្ចប្រតិបត្តិការ ផ្តល់សន្ទនីយភាពដោយមានការធានា (Liquidity-providing collagenized operation) ។ ធនាគារជាតិនៃកម្ពុជា បានតម្រូវអោយស្ថាប័នដែលទទួលបានមូលនិធិ ផ្តល់យ៉ាងតិច១០%នៃប្រាក់កម្ចីរបស់ខ្លួន ជាប្រាក់រៀល។ យោងតាមរបាយការណ៍ធនាគារជាតិ ដែលផ្តល់ទៅសារព័ត៌មានបណ្តាញសង្គមហ្វេសប៊ុក និងឯកសារស្ថិតិថ្មីៗ បានអោយដឹងថាប្រាក់រៀលដែលផ្តល់ដោយប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) នៅក្នុងរយៈពេល៦ខែដំបូងក្នុងឆ្នាំ២០១៨ មាន២,៦ដង ខ្ពស់ជាងចំនួនដែលធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំ២០១៧។

### តារាងប្រចាំសប្តាហ៍៖ ការផលិតកៅស៊ូសរុបនៅកម្ពុជា ២០០៩-២០១៧

តារាងប្រចាំសប្តាហ៍ខាងក្រោមនេះ បង្ហាញពីកំណើនស្ទើរតែថេរនៅក្នុងវិស័យកៅស៊ូនៅកម្ពុជានៅក្នុងកំឡុងទស្សវត្សរ៍ចុងក្រោយ ដូចដែលបានបង្ហាញនៅក្នុង របាយការណ៍ប្រចាំឆ្នាំសម្រាប់កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២០១៦-២០១៧។ ទោះបីជាទិន្នផលកៅស៊ូជាមធ្យម នៅរក្សាលំនឹងក្នុងកំឡុងពេលដដែលនោះ ផលិតកម្មមានការកើនឡើងយ៉ាងខ្លាំង បើគិតពីការកើនឡើងនូវផ្ទៃដីដាំដុះ ដែលមានកំណើនជាមធ្យម១៦.៦%រៀងរាល់ឆ្នាំ។

កៅស៊ូដែលដាំនៅកម្ពុជា ត្រូវបាននាំចេញស្ទើរតែទាំងអស់។ ការនាំចេញកៅស៊ូមានកំណើន២២%ជាមធ្យម រៀងរាល់ឆ្នាំ។

### ផលិតកម្មកៅស៊ូនៅកម្ពុជា (ទិន្នផលនៅលើអក្សខាងស្តាំ)




ប្រភព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

## វៀតណាមជាប់ជាដៃគូពាណិជ្ជកម្មអាស៊ានធំបំផុតរបស់ចិន បន្ទាប់ពីម៉ាឡេស៊ី

ពាណិជ្ជកម្មរវាងចិននិងវៀតណាមបានកើនឡើងដល់ ១១,២ ប៊ីលានដុល្លារក្នុងខែមិថុនា ពោលគឺកើនឡើងលើសពីពាណិជ្ជកម្មរវាងចិននិង ម៉ាឡេស៊ី ដែលមានចំនួន ៩,៣ ប៊ីលានដុល្លារ។ ប្រទេសម៉ាឡេស៊ីបានកាន់តំណែងជាដៃគូពាណិជ្ជកម្មក្នុងអាស៊ានធំបំផុតរបស់ចិន អស់រយៈពេលជាច្រើនឆ្នាំ ដូចដែលបានរាយការណ៍ដោយ សារព័ត៌មានភ្នំពេញប៉ុស្តិ៍។

ពាណិជ្ជកម្មទ្វេភាគីរវាងចិននិងវៀតណាមបានកើនឡើង ២៨,៨% នៅឆមាសទីមួយនៃឆ្នាំ២០១៨ ខណៈដែលពាណិជ្ជកម្មរវាងចិននិងម៉ាឡេស៊ីបានកើនឡើង ១៥,៥%។

ការរីកចម្រើនយ៉ាងឆាប់រហ័សនៃពាណិជ្ជកម្មរវាងចិន និងវៀតណាមជាលទ្ធផលនៃគោលនយោបាយព្រំដែនដើម្បីបង្កើនការនាំចូលផលិតផលកសិកម្មចូលទៅក្នុងប្រទេសចិន។

# សេដ្ឋកិច្ចអាមេរិក និងធនាគារសហព័ន្ធ

## កំណើនផលិតផលក្នុងស្រុកសរុបរបស់សហរដ្ឋអាមេរិកនៅក្នុង ត្រីមាសទី២ កើនដល់ ៤,១%

សេដ្ឋកិច្ចរបស់អាមេរិកបានកើនឡើងក្នុងអត្រាប្រចាំឆ្នាំ ៤,១% នៅក្នុងត្រីមាសទី២ នៃឆ្នាំ ២០១៨ ដែលជាកំណើនខ្ពស់បំផុតក្នុងរយៈពេលជិតបួនឆ្នាំ (ការិយាល័យវិភាគសេដ្ឋកិច្ច) ។ កំណើននេះយ៉ាងហោចណាស់មួយផ្នែក ត្រូវបានជំរុញដោយកសិករអាមេរិករួសរាន់នាំចេញសណ្តែកសៀង មុនការសងសឹកពន្ធគយដែលបានចាប់ផ្តើមកាលពីដើមខែកក្កដា។

លោកប្រធានាធិបតី ត្រាំ (Trump) បានប្រញាប់ប្រញាល់ទទួលយកគុណសម្បត្តិសម្រាប់ការរីកចម្រើននេះ ដោយលើកឡើងថា "យើងបានសម្រេចនូវការផ្លាស់ប្តូរសេដ្ឋកិច្ចជាប្រវត្តិសាស្ត្រ"។ សារព័ត៌មានជាច្រើន ដូចជាកាសែតញូវយ៉កថែមស៍ បានចោទសួរពីភាពត្រឹមត្រូវនៃពាក្យសម្តីរបស់លោកប្រធានាធិបតី ត្រាំ (Trump) ។

# ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ព័ត៌មានទិន្នន័យ និងព្រឹត្តការណ៍សេដ្ឋកិច្ចសម្រាប់សប្តាហ៍បន្ទាប់រួមមាន៖ ការសម្រេចទៅលើអត្រាការប្រាក់របស់ធនាគារជាតិនៅប្រទេសថៃ និងហ្វីលីពីន ។

ខាងក្រោមនេះគឺជាកាលបរិច្ឆេទ ទិន្នន័យ និងការវិវត្តន៍នានាដែលក្រុមការងារបណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធ នឹងបន្តតាមដាននិងស្រាវជ្រាវនៅសប្តាហ៍បន្ទាប់។

<u>ថ្ងៃច័ន្ទ ទី០៦ ខែសីហា</u>

- ផលិតផលក្នុងស្រុកសរុប(ផ.ស.ស) របស់ឥណ្ឌូនេស៊ី ក្នុងត្រីមាសទី២ ឆ្នាំ២០១៨
- ភាពជឿជាក់លើធុរៈកិច្ចរបស់ប្រទេសឥណ្ឌូនេស៊ី ត្រីមាសទី២ ឆ្នាំ២០១៨
- ភាពជឿជាក់របស់អ្នកប្រើប្រាស់ ក្នុងប្រទេសឥណ្ឌូនេស៊ី សម្រាប់ខែកក្កដា
- ទុនបម្រុងអន្តរជាតិ នៅតៃវ៉ាន់ នៅខែកក្កដា

<u>ថ្ងៃអង្គារ ទី០៧ ខែសីហា</u>

- ការចំណាយសម្រាប់គ្រួសារ ប្រទេសជប៉ុន នៅខែមិថុនា
- អតិផរណានៅហ្វីលីពីន នៅខែកក្កដា
- ផលិតកម្មឧស្សាហកម្មនៅហ្វីលីពីន នៅខែមិថុនា
- តុល្យភាពពាណិជ្ជកម្ម ប្រទេសប្រ៊ុយណេ ខែសីហា
- សន្ទស្សន៍តម្លៃលក់រាយ ប្រទេសហ្វីលីពីន ខែមិថុនា
- អតិផរណានៅតៃវ៉ាន់ នៅខែកក្កដា
- តុល្យភាពពាណិជ្ជកម្មនៅតៃវ៉ាន់ នៅខែកក្កដា
- ទុនបម្រុងអន្តរជាតិនៅសឹង្ហបុរី នៅខែកក្កដា

<u>ថ្ងៃពុធ ទី០៨ ខែសីហា</u>

- គណនីចរន្តរបស់ជប៉ុន នៅខែមិថុនា
- តុល្យភាពពាណិជ្ជកម្មរបស់ហ្វីលីពីន នៅខែមិថុនា
- តុល្យភាពពាណិជ្ជកម្មរបស់ចិន នៅខែកក្កដា
- ការសម្រេចលើអត្រាការប្រាក់របស់ថៃ
- ការលក់រាយរបស់ឥណ្ឌូនេស៊ី នៅខែមិថុនា

<u>ថ្ងៃព្រហស្បត្តិ៍ ទី០៩ ខែសីហា</u>

- អត្រាអតិផរណារបស់ចិន នៅខែកក្កដា
- កំណើនផ.ស.ស. របស់ហ្វីលីពីន ត្រីមាសទី២ ឆ្នាំ២០១៨
- ការសម្រេចទៅលើអត្រាការប្រាក់របស់ហ្វីលីពីន
- សន្ទស្សន៍ថ្លៃអចលនទ្រព្យនៅឥណ្ឌូនេស៊ី ត្រីមាសទី២ ឆ្នាំ២០១៨

<u>ថ្ងៃសុក្រ ទី១០ ខែសីហា</u>

- កំណើនផ.ស.ស. របស់ជប៉ុន នៅត្រីមាសទី២ ឆ្នាំ២០១៨
- សន្ទស្សន៍ថ្លៃសម្រាប់អ្នកផលិត ប្រទេសជប៉ុន ខែកក្កដា
- ផលិតកម្មឧស្សាហកម្មនៅម៉ាឡេស៊ី នៅខែមិថុនា
- អត្រាអ្នកគ្មានការងារធ្វើ នៅម៉ាឡេស៊ី នៅខែមិថុនា
- ការលក់រាយនៅសឹង្ហបុរី នៅខែមិថុនា
- ទុនបម្រុងអន្តរជាតិនៅប្រទេថៃ នៅខែកក្កដា
- កំណើនផ.ស.ស.នៅហុងកុង នៅត្រីមាសទី២ ឆ្នាំ២០១៨
- គណនីចរន្តរបស់ឥណ្ឌូនេស៊ី នៅត្រីមាសទី២ ឆ្នាំ២០១៨៕

*************************